# សហគមន៍ខ្មែរកម្ពុជាក្រោម

**KHMER KAMPUCHEA KROM COMMUNITY**
**LA COMMUNAUTÉ DU KHMER KAMPUCHEA KROM**

លេខ............ ............ ស.ខ.ក.ក.

## សេចក្តីថ្លែងការណ៍

អង្គការ សមាគមខ្មែរកម្ពុជាក្រោម មានសេចក្តីព្រួយបារម្ភយ៉ាងខ្លាំងចំពោះសុវត្ថិភាពរបស់ព្រះតេជគុណទីម សាខន ដែលត្រូវបានអាជ្ញាធរខ្មែរចាប់បញ្ជូនឱ្យអាជ្ញាធរវៀតណាម កាលពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៧។ ហេតុផលដែលលើកឡើងដោយអ្នកនាំពាក្យក្រសួងមហាផ្ទៃក្នុងការចាប់បញ្ជូនខ្លួនព្រះតេជគុណទីម សាខន ពុំបានសមស្របទៅនឹងសភាពការណ៍ពិតឡើយពីព្រោះ:

១- ក្រោយពីចាប់ផ្សឹកព្រះតេជគុណទីម សាខននៅសាលាខេត្តតាកែវភ្លាម មានជនមិនស្គាល់មុខមួយក្រុម បាននាំខ្លួនព្រះអង្គចេញបាត់ ដោយមិនដឹងនាំយកទៅទីណា និងធ្វើអ្វីចំពោះព្រះអង្គខ្លះ ។

២- ម្តាយឪពុកបងប្អូនព្រះតេជគុណទីម សាខនមករស់នៅក្បែរវត្តភ្នំដិនទាំងអស់ តើព្រះអង្គសុំយាងមកទៅស្រុកកំណើតនៅកម្ពុជាក្រោម ដើម្បីជួបអ្នកណា?

៣- សម្តេចសង្ឃនាយកបានចោទប្រកាន់ថា ព្រះតេជគុណទីម សាខន ធ្វើសកម្មភាពបំបែកបំបាក់មិត្តភាពកម្ពុជា វៀតណាម មានន័យថាប្រឆាំងវៀតណាម ហេតុអ្វីព្រះអង្គចង់ទៅប្រទេសវៀតណាមរកសេចក្តីស្លាប់?

ការចាប់បញ្ជូនខ្លួនព្រះតេជគុណទីម សាខនទៅប្រទេសវៀតណាម ជាការជុំយនឹងរដ្ឋធម្មនុញ្ញមាត្រាពាក់ទាំងស្រុង និងជាការបំបាក់ស្មារតីនៃការតស៊ូ ដើម្បីសិទ្ធិសេរីភាពដោយអហិង្សារបស់អង្គការ-សមាគមខ្មែរកម្ពុជាក្រោមដោយចេតនាយ៉ាងពិតប្រាកដ ។

អង្គការ-សមាគមខ្មែរកម្ពុជាក្រោមសូមអំពាវនាវដល់អង្គទូត អង្គការជាតិ អន្តរជាតិ ជាពិសេស ស្នងការជាន់ខ្ពស់អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ជួយតាមឃ្លាំមើលឱ្យបានដិតដល់ចំពោះសុវត្ថិភាពរបស់ព្រះតេជគុណទីម សាខន និងសូមអំពាវនាវដល់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាចាត់វិធានការជាបន្ទាន់នាំយកព្រះតេជគុណទីម សាខនត្រឡប់មកវិញ ។

ជាមួយគ្នានេះ អង្គការ-សមាគមខ្មែរកម្ពុជាក្រោម សូមអំពាវនាវដល់សម្តេចអគ្គមហាសង្ឃាធិបតី និងសម្តេចព្រះសង្ឃនាយក ព្រមទាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បញ្ឈប់រាល់ការគំរាមកំហែង និងចាប់ផ្សឹកព្រះសង្ឃខ្មែរកំណើតកម្ពុជាក្រោម និងបញ្ជូនខ្លួនទៅប្រទេសវៀតណាមបន្តទៀត ។

ភ្នំពេញ, ថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៧

តំណាងអង្គការ-សមាគមខ្មែរកម្ពុជាក្រោម

ថាច់ សេដ្ឋា

ប្រធានសហគមន៍ខ្មែរកម្ពុជាក្រោម

ព័ត៌មានបន្ថែមសូមទាក់ទង:

០១២ ៩០៨ ៨៨២

០១២ ៩១៨ ៦៩២

០១២ ៨៥៥ ២៧៥

ភូមិគ្រឹះលេខ៩៦ , ផ្លូវ៣៧១ , ភូមិត្រពាំងឈូក , សង្កាត់ទឹកថ្លា , ខណ្ឌឫស្សីកែវ , រាជធានីភ្នំពេញ
ទូរស័ព្ទ-ទូរសារលេខ : (៨៥៥) ២៣ ៩៩៥ ៩៨១, ១២ ៨៥១ ៩៩១ / ៩០ ៨៨ ៨២.
អ៊ីមែល: kkcommunity@camintel.com or k.k.k.c@camitel.com; website: http://khmerkromngo.org